Australian Government

NATIONAL BOWEL CANCER SCREENING PROGRAM

C001LC – 7/2025 – Khmer I ភាសាខ្មែរ

# លិខិតគំរូប៉ុណ្ណោះ

**ធ្វើតេស្តនេះ ហើយប្រគល់វាមកវិញក្នុងរយៈពេល 2 សប្តាហ៍ ឬឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន**

**<នាមខ្លួន> ដល់ពេលធ្វើតេស្តពិនិត្យមើលពោះវៀនដោយឥតគិតថ្លៃរបស់អ្នកហើយ។**

## ការធ្វើតេស្តនេះអាចជួយសង្គ្រោះជីវិតរបស់អ្នកបាន

- ជំងឺមហារីកពោះវៀនឆក់យកជីវិតមនុស្សច្រើនជាងជំងឺមហារីកដោះ ស្បែក ឬក្រពេញប្រូស្តាត - ហើយអាយុគឺជាកត្តាហានិភ័យធំបំផុត។
- វាអាចវិវឌ្ឍដោយគ្មានរោគសញ្ញា ឬមានប្រវត្តិគ្រួសារនៃជំងឺមហារីកពោះវៀន ដូច្នេះវាជារឿងសំខាន់ដែលអ្នកត្រូវធ្វើតេស្ត ទោះបីជាអ្នកមានអារម្មណ៍មាំមួន និងមានសុខភាពល្អក៏ដោយ។
- ប្រសិនបើរកឃើញទាន់ពេលវេលា ករណីជំងឺមហារីកពោះវៀនជាង 90% អាចព្យាបាលបានដោយជោគជ័យ។

## ការធ្វើតេស្តនេះគឺរហ័ស មានអនាម័យ និងងាយស្រួលធ្វើ

អ្វីគ្រប់យ៉ាងដែលអ្នកត្រូវការគឺមាននៅក្នុងកញ្ចប់ធ្វើតេសត្ត រួមទាំងការណែនាំលម្អិតផងដែរ។



1 ប្រមូលសំណាកតូចៗ ចំនួន 2 ពីលាមក 2 លើក ដាច់ដោយឡែកពីគ្នា។



2 រក្សាទុកសំណាករបស់អ្នកនៅកន្លែងត្រជាក់។ កុំបង្កក។



3 សូមផ្ញើសំណាករបស់អ្នកមកយើងវិញ។

ស្កេនកូដ QR នេះដើម្បីមើលវីដេអូអំពីរបៀបធ្វើតេស្ត។

លទ្ធផលរបស់អ្នកនឹងត្រូវបានផ្ញើទៅអ្នក និងវេជ្ជបណ្ឌិតរបស់អ្នកក្នុងរយៈពេល 4 សប្តាហ៍ បន្ទាប់ពីអ្នកផ្ញើសំណាករបស់អ្នក។

កម្មវិធីនេះបញ្ចប់នៅអាយុ 74 ឆ្នាំ ដូច្នេះនេះគឺជាកញ្ចប់ធ្វើតេស្តចុងក្រោយដែលយើងនឹងផ្ញើទៅអ្នក។ ប្រសិនបើអ្នកមានការព្រួយបារម្ភជាបន្តបន្ទាប់អំពីជំងឺមហារីកពោះវៀន សូមពិភាក្សាជាមួយវេជ្ជបណ្ឌិតរបស់អ្នក ដែលអាចពិចារណាលើស្ថានភាពសុខភាពរបស់អ្នក និងផ្តល់ដំបូន្មានអំពីជម្រើសក្នុងការពិនិត្យសមស្រប។

**កុំភ្លេចធ្វើតេស្ត - ដាក់ភ្ជាប់លិខិតនេះនៅលើទូទឹកកក និងកញ្ចប់ធ្វើតេស្តរបស់អ្នកនៅជិតបង្គន់**

**សម្រាប់ព័ត៌មានបន្ថែមអំពីការពិនិត្យរកមើលជំងឺមហារីកពោះវៀន**

ស្កេនកូដ QR នេះដើម្បីចូលមើលគេហទំព័រ www.health.gov.au/nbcsp

សូមចូលមើលបញ្ជីពិនិត្យរកមើលជំងឺមហារីកថ្នាក់ជាតិនៅ www.ncsr.gov.au ឬហៅទូរសព្ទទៅលេខ 1800 627 701

របៀបដែលយើងប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក៖ www.ncsr.gov.au/privacy